ការពិភាក្សានិងប្តូរយោបល់នៅក្នុងលក្ខណៈព្យាបាលតម្រូវឲ្យមានការរៀបចំសំរាប់ដំណើរការដែលដាក់ការណាត់ជួបជាច្រើនដង ដោយមានពេលវេលាទៀងទាត់នៅក្រោមការយល់ព្រមអំពីអតិថិជនផងដែរ ឧទាហរណ៍ ការណាត់ជួបដែលមានរយៈពេលមួយម៉ោង(មួយវគ្គជួប)នៅក្នុងកំឡុងពេលមួយសប្តាហ៍ ឬ ពីរសប្តាហ៍ម្តងជាដើម។ ការណាត់ជួបអាចប្រព្រឹត្តទៅជាច្រើនដងនៅក្រោមការកំណត់វគ្គជួបពី ៧ ទៅ ៨ វគ្គ ហើយនិងអាចរហូតដល់ជាច្រើនវគ្គជួបនៅក្នុងកម្លុងវែងផងដែរ។ នៅក្នុងដំណើរការនៃការព្យាបាលនេះ អ្នកពិភាក្សានិងប្តូរយោបល់អាចធ្វើសហប្រតិបត្តិការរួមការព្យាបាលជាមួយអ្នកឯកទេសផ្សេងៗទៀតដែលផ្តល់នូវជំនួយសំរាប់បំពេញសេចក្តីត្រូវការរបស់អតិថិជនដែលមិនបានទទួលតាមរយៈដំណើរការនៃការពិភាក្សានិងប្តូរយោបល់។ អ្នកឯកទេសទាំងនោះអាចរាប់បញ្ចូលដូចជា៖ វេជ្ជបណ្ឌិតចិត្តសាស្ត្រ, វេជ្ជបណ្ឌិតសរីរាង្គ, វេជ្ជបណ្ឌិតវេជ្ជសាស្ត្រ, សង្គមកិច្ច, បុគ្គលិកសុខាភិបាល ឬ សហគមន៍, គិលានុបដ្ឋាយិកា, សិរីរបរិហារជាដើម។

## ៤ – ការបញ្ជូនទៅជួបជាមួយអ្នកពិភាក្សានិងប្តូរយោបល់

ការទទួលជំនួយផ្នែកខាងការពិភាក្សានិងប្តូរយោបល់អាចប្រព្រឹត្តបានដោយមានការបញ្ជូនរបស់ក្រសួង, ស្ថាប័នសាធារណៈឬឯកជន, អ្នកឯកទេសខាងសុខភាព, បុគ្គលិកសុខាភិបាល ឬ សហគមន៍។ អតិថិជនមានសិទ្ធិធ្វើការទាក់ទងដោយផ្ទាល់ជាមួយអ្នកពិភាក្សានិងប្តូរយោបល់ដើម្បីសុំរៀបចំការណាត់ជួប។ អ្នកពិភាក្សានិងប្តូរយោបល់ដែលមាននាទីផ្តល់ពត៌មានអាចធ្វើការបញ្ជូនអតិថិជនរបស់ខ្លួនបន្ទាប់ពីបានពិនិត្យឃើញមានសេចក្តីត្រូវការជាចាំបាច់អំពីអ្នកពិភាក្សានិងប្តូរយោបល់ដែលមាននាទីព្យាបាលនៅក្នុងផ្នែកណាមួយ។ ការបញ្ជូនជាទូរទៅចាំបាច់ត្រូវតែមានការយល់ព្រមអំពីសាមីខ្លួនអតិថិជនផងដែរ។

## ៥ – អ្នកពិភាក្សានិងប្តូរយោបល់ជាអ្នកណាដែរ?

អ្នកពិភាក្សានិងប្តូរយោបល់ និង អ្នកព្យាបាលខាងផ្លូវចិត្តអាចជាអ្នកដែលមានវិជ្ជាជីវៈជា៖ វេជ្ជបណ្ឌិតវេជ្ជសាស្ត្រ, វេជ្ជបណ្ឌិតចិត្តសាស្ត្រ, ចិត្តវិទូ, សង្គមកិច្ច, គិលានុបដ្ឋាយិកាជាដើម។ល។ដែលបានទទួលនូវការសិក្សាបន្ថែមអំពីបច្ចេកទេស និង បែបបទនៃការពិភាក្សានិងប្តូរយោបល់ ហើយនិងវិធីព្យាបាលផ្លូវចិត្តបានត្រឹមត្រូវ។ ការសិក្សានិងហាត់ហ្វឹកហ្វឺន, អនុវត្តន៍ និង ការដកពិសោធន៍ត្រូវបានទទួលការណែនាំ, សំរួល និង ត្រួតពិនិត្យយ៉ាងត្រឹមត្រូវហ្មត់ចត់អំពីអ្នកឯកទេសនិងជំនាញការខាងផ្នែកការពិភាក្សានិងប្តូរយោបល់ ហើយនិងការព្យាបាលខាងផ្លូវចិត្ត។

អ្នកពិភាក្សានិងប្តូរយោបល់ និង អ្នកព្យាបាលខាងផ្លូវចិត្តមានប្រចាំនៅក្នុងមន្ទីរពេទ្យរដ្ឋ និង ឯកជន, នៅក្នុងក្រសួង ឬ ផ្នែកជំនួយសំរាប់ការព្យាបាលផ្លូវចិត្ត, ស្ថាប័នរដ្ឋដូចជា តុលាការខាងច្បាប់គ្រួសារ, មជ្ឈមណ្ឌលសុខភាពសហគមន៍ជាដើម។
អ្នកពិភាក្សានិងប្តូរយោបល់ និង អ្នកព្យាបាលខាងផ្លូវចិត្តមួយចំនួនបើកមន្ទីរព្យាបាលឯកជនដាច់ដោយឡែកអំពីស្ថាប័ន។

**ការពិភាក្សានិងប្តូរយោបល់មានលក្ខណៈជំនួយចំពោះការថែរទាំសុខភាពខាងផ្លូវចិត្តដែលអាចផ្តល់ជាមធ្យោបាយសំរាប់ការការពារនូវវិបត្តិផ្លូវចិត្តបាន។**

**ការពិភាក្សានិងប្តូរយោបល់ មិនមែនសំដៅទៅលើការព្យាបាលអ្នកវិកលចរិតនោះទេ។**

## ៦ – ឯកទេសរបស់អ្នកពិភាក្សានិងប្តូរយោបល់

អ្នកពិភាក្សានិងប្តូរយោបល់ និង អ្នកព្យាបាលផ្លូវចិត្តអនុវត្តន៍ និងរៀនបន្ថែមនូវផ្នែកណាមួយដែលពេញចិត្តនិងចូលចិត្តដើម្បីដកពិសោធន៍និងយកជំនាញការនៅក្នុងផ្នែកនោះ ដូចជា៖ ផ្នែកខាងបំពារបំពានខាងផ្លូវភេទ, ផ្នែកខាងបញ្ហាគ្រួសារនិងក្មេងៗ, ផ្នែកខាងសុរានិងគ្រឿងញៀន, ភ័យបារម្ភស្បាតនិងជនភៀសខ្លួន, ផ្នែកខាងសុខភាពផ្លូវចិត្តយុវជនជាដើម។

# ការពិភាក្សានិងប្តូរយោបល់
# COUNSELLING
(សំណៅថ្មី)

រក្សាការសម្ងាត់ទុកជូន
មិនមានភាពលំអៀង